# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អវតក/អជសដ

ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**

ដាក់ជូន៖ អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម៖ **បារាំង**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០១៣

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date):______08-May-2013, 15:08______
CMS/CFO:______Sann Rada______

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿង និងឯកសារ៖

ហត្ថលេខា៖

---

## សំណើសុំឲ្យមានកិច្ចប្រជុំរៀបចំសវនាការដើម្បីកំណត់ប្រក្រតិទិនច្បាស់លាស់មួយសម្រាប់ ដំណាក់កាលសវនាការដែលនៅសេសសល់ ក្នុងសំណុំរឿង ០០២/០១

---

ដាក់ដោយ៖

**មេធាវីការពារក្ដីលោក ខៀវ សំផន**

មេធាវី គង់ សំអុន

មេធាវី Anta GUISSÉ

មេធាវី Arthur VERCKEN

មេធាវី Jacques VERGÈS

ដាក់ជូន៖

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យូរ ឧត្តរា

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យ៉ា សុខន

**ជំនួយការ៖**

លោកស្រី សេង សុជាតា

កញ្ញា Marie CAPOTORTO

កញ្ញា Shéhérazade BOUARFA

កញ្ញា Mathilde CHIFFERT

កញ្ញា Vera MANUELLO

កញ្ញា អ៊ូច ស្រីផាត់

កញ្ញា សុគន្ធ ម៉ូនីកា

លោក Pierre TOUCHE

កញ្ញា Blandine ZELLER

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Andrew CAYLEY

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

**ក្រុមមេធាវីការពារក្តីទាំងអស់**

# សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង

១. កាលពីថ្ងៃទី ៨ ខែ មេសា ឆ្នាំ ២០១៣ អង្គជំនុំជម្រះតុលាការកំពូល ("តុលាការកំពូល") បានចេញសេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីវិសាលភាពនៃសំណុំរឿង ០០២/01[1]។

២. នៅថ្ងៃទី ១៤ ខែ មីនា ពេលគឺដប់ថ្ងៃបន្ទាប់ពីបានចូលសម្រាកព្យាបាលជម្ងឺនៅមន្ទីរពេទ្យមិត្តភាពកម្ពុជា-សូវៀត លោក អៀង សារី ក៏បានទទួលមរណភាព ដែលបណ្តាលឱ្យមានការរំលត់បណ្តឹងអាជ្ញាចំពោះគាត់។

៣. នៅថ្ងៃទី ២៦ ខែ មេសា អង្គជំនុំជម្រះសាលាដំបូង ("អង្គជំនុំជម្រះ") បានចេញសេចក្តីសម្រេចថ្មីរបស់ខ្លួនមួយពាក់ព័ន្ធនឹងការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ ("ដីកាបំបែកកិច្ចដំណើរការនីតិវិធីថ្មី")[2]។

៤. នៅក្នុងសេចក្តីសម្រេចនេះ អង្គជំនុំជម្រះបានធ្វើការបញ្ជាក់លម្អិតអំពីសម្អាងហេតុ ដែលតាមរយៈនោះ អង្គជំនុំជម្រះយល់ឃើញថា វាជាប្រយោជន៍ដល់យុត្តិធម៌ក្នុងការកំណត់នូវព្រំដែនវិសាលភាពនៃរឿងក្តីបច្ចុប្បន្ន ដូចដែលអង្គជំនុំជម្រះធ្លាប់បានកំណត់រួចមកហើយនៅក្នុងសេចក្តីសម្រេចមុនៗរបស់ខ្លួន។

៥. ក្នុងការធ្វើដូច្នេះ អង្គជំនុំជម្រះពុំបានសម្រេចតាមសំណើសុំនានារបស់សហព្រះរាជអាជ្ញា របស់ដើមបណ្តឹងរដ្ឋប្បវេណី និងរបស់មេធាវីការពារក្តីលោក នួន ជា ដែលស្នើសុំឱ្យមានការបន្ថែម

---

[1] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីវិសាលភាពនៃសំណុំរឿងលេខ ០០២/០១ ឯកសារ **E165/5/1/13** ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣។

[2] *សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣* ឯកសារ **E284** ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣។

ភ័ស្តុតាងផ្សេងៗទៀតទៅក្នុងសំណុំរឿង ០០២/០១ រួមទាំងសេចក្តីសម្រេចបន្ទាន់ស្តីអំពីអង្គហេតុសរុបដែលត្រូវបានចោទប្រកាន់ក្នុងដីកាដំណោះស្រាយនោះទេ។

៦. សម្អាងហេតុមួយក្នុងចំណោមសម្អាងហេតុចម្បងនានារបស់អង្គជំនុំជម្រះ គឺអង្គជំនុំជម្រះយល់ឃើញថា ការលាតសន្ធឹងថ្មីនូវវិសាលភាពនៃរឿងក្តីនឹងបង្កើតឲ្យមានជាផលវិបាកយ៉ាងខ្លាំងដល់កិច្ចគ្រប់គ្រងសវនាការ[3]។

៧. អង្គជំនុំជម្រះបានលើកឡើងថា អង្គជំនុំជម្រះកំពុងតែស្ថិតក្នុងដំណាក់កាលដកខ្លួនចេញអំពីភារកិច្ចក្នុងការចេញសេចក្តីសម្រេចនានាដែលនៅសេសសល់ពាក់ព័ន្ធនឹងភាពដែលអាចទទួលយកបាននៃឯកសារដែលត្រូវបានស្នើដាក់បញ្ចូលក្នុងកិច្ចពិភាក្សាដេញដោល។ ដូច្នេះ ក្នុងការអនុញ្ញាតឲ្យភាគីធ្វើសំណើដាក់បញ្ចូលឯកសារភ័ស្តុតាងសាជាថ្មីទៅក្នុងសំណុំរឿង គឺជាការបន្ថែមការងារដល់អង្គជំនុំជម្រះ និងបង្កើតឲ្យមានជាការអូសបន្លាយដល់កិច្ចដំណើរការនីតិវិធី។

៨. ជាមួយគ្នានេះ អង្គជំនុំជម្រះបានអះអាងថា អង្គជំនុំជម្រះបានចាប់ផ្តើមរៀបចំប្រក្រតិទិនសម្រាប់ផ្នែកនានាដែលនៅសេសសល់ចុងក្រោយនៃរឿងក្តី មានដូចជាផ្នែកដែលពាក់ព័ន្ធនឹងបុគ្គលិកលក្ខណៈរបស់ជនជាប់ចោទ និងផលប៉ះពាល់នៃឧក្រិដ្ឋកម្មទៅលើជនរងគ្រោះ[4]។ អង្គជំនុំជម្រះក៏បានលើកឡើងផងដែរថា ខ្លួនកំពុងពិចារណាលើអត្តសញ្ញាណរបស់អ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីនានាដែលខ្លួននឹងត្រូវធ្វើការស្តាប់សក្ខីកម្មនាពេលអនាគត។ ពាក់ព័ន្ធនឹងអ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីទាំងឡាយដែលអង្គជំនុំជម្រះមិនបានធ្វើការកោះហៅឲ្យចូលខ្លួនមកផ្តល់សក្ខីកម្ម អង្គជំនុំជម្រះនឹងផ្តល់នូវហេតុផលនានាដែលអង្គជំនុំជម្រះយល់ឃើញថាមិនមានសារៈសំខាន់ក្នុងការកោះហៅពួកគេទាំងនោះ[5]។

---

[3] *សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣* ឯកសារ **E284** ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ កថាខណ្ឌ ១៤៤។

[4] ដូចយោងខាងលើ។

[5] *សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣* ឯកសារ **E284** ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ កថាខណ្ឌ ៤៤។

៩. នៅថ្ងៃទី ៦ ខែ ឧសភា មន្ត្រីច្បាប់មួយរូបនៃអង្គជំនុំជម្រះសាលាដំបូងបានផ្ញើអ៊ីម៉ែល[6]មួយជូនដំណឹងដល់ភាគីនៃរឿងក្តីអំពី *"ក្រុមសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដែលនឹងត្រូវចូលខ្លួនមកចំពោះមុខអង្គជំនុំជម្រះ នៅពេលមានការធ្វើសេចក្តីសន្និដ្ឋានលើសក្ខីកម្មរបស់អ្នកជំនាញលោក Philip Short* [7]"។ អ៊ីម៉ែលនោះបានបង្ហាញអំពីគម្រោងក្នុងការកោះហៅសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន ដែលពួកគេត្រូវបានគេកោះហៅឱ្យចូលខ្លួនក្នុងដំណាក់កាលនៃការស្តាប់សក្ខីកម្មពាក់ព័ន្ធនឹងផលប៉ះពាល់នៃឧក្រិដ្ឋកម្មប្រព្រឹត្តមកលើជនរងគ្រោះ។

១០. មេធាវីការពារក្តីលោក ខៀវ សំផន យល់ច្បាស់ថាបញ្ជីនោះគឺជាបញ្ជីបណ្តោះអាសន្ន។ ជាក់ស្តែងដូចទៅនឹងអ្វីដែលអង្គជំនុំជម្រះធ្លាប់បានប្រកាស សហមេធាវីការពារក្តីលោក ខៀវ សំផន ក៏ដូចជាភាគីដទៃទៀតនៃរឿងក្តីដែរ កំពុងរង់ចាំបញ្ជីឈ្មោះស្ថាពរនៃសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីនៅសេសសល់ដែលត្រូវកោះហៅឱ្យចូលខ្លួនមកផ្តល់សក្ខីកម្មនោះ។ អង្គជំនុំជម្រះបានអះអាងជាច្រើនលើកច្រើនសាថា សំណុំរឿង ០០២/០១ បានឈានមកដល់ដំណាក់កាលចុងក្រោយហើយ[8]។ ដូច្នេះលោក ខៀវ សំផន អាចស្នើសុំដោយស្របច្បាប់ដល់អង្គជំនុំជម្រះឱ្យជូនដំណឹងដល់ភាគីអំពីបញ្ជីឈ្មោះស្ថាពរនៃសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីដែលអង្គជំនុំជម្រះមានបំណងកោះហៅឱ្យចូលខ្លួនមកផ្តល់សក្ខីកម្ម។ បញ្ជីឈ្មោះនោះនឹងអនុញ្ញាតឱ្យមេធាវីការពារក្តីអាចត្រៀមរៀបចំការការពារក្តីរបស់ខ្លួនបានល្អប្រសើរនៅពេលដែលមានការចូលមកផ្តល់សក្ខីកម្មនោះ។

១១. នៅក្នុងដីកាបំបែកសំណុំរឿងថ្មី អង្គជំនុំជម្រះបានជូនដំណឹងដល់ភាគីទាំងអស់ថា អង្គជំនុំជម្រះគ្រោងរៀបចំកិច្ចប្រជុំរៀបចំសវនាការនាពេលណាមួយក្នុងឆ្នាំនេះដើម្បីធ្វើការពិភាក្សាលើលទ្ធភាព

---

[6] អ៊ីមែលរបស់មន្ត្រីច្បាប់របស់អង្គជំនុំជម្រះសាលាដំបូង Roger Phillips កម្មវត្ថុ៖ «*Notice of next witnesses/Civil parties*» ចុះថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៣។

[7] ដូចយោងខាងលើ។

[8] សេចក្តីសម្រេចលើសំណើសុំដោះលែងលោក ខៀវ សំផន ឱ្យនៅក្រៅឃុំជាបន្ទាន់ ឯកសារ **E275/1** ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ កថាខណ្ឌ ២៣។

នានាដែលអង្គជំនុំជម្រះ និងភាគីនៃរឿងក្តីមានជាក់ស្តែង ក្នុងការបន្តជំនុំជម្រះនាដំណាក់កាលក្រោយៗទៀតនៃរឿងក្តី ០០២[9]។ ដោយឡែក មេធាវីការពារក្តីលោក ខៀវ សំផន មានបំណងស្នើសុំដល់អង្គជំនុំជម្រះឲ្យធ្វើការរៀបចំជាអាទិភាពចំបង និងចាប់ពីពេលនេះតទៅ នូវកិច្ចប្រជុំរៀបចំសវនាការដើម្បីស្តាប់ហេតុផលរបស់ភាគី មុនពេលដែលអង្គជំនុំជម្រះធ្វើការកំណត់ជាស្ថាពរនូវវិធីសាស្ត្រ ដែលអង្គជំនុំជម្រះមានបំណងធ្វើការសន្និដ្ឋានលើដំណាក់កាលបច្ចុប្បន្ននៃសំណុំរឿង ០០២[10]។ ដើម្បីធានាឲ្យមានការរៀបចំសវនាការប្រកបដោយប្រសិទ្ធភាព ទាំងចំពោះអង្គជំនុំជម្រះ និងទាំងចំពោះភាគីនៃរឿងក្តី ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន សូមស្នើឲ្យមានការដាក់បញ្ចូលទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំរៀបចំសវនាការ នូវចំណុចនានាដូចខាងក្រោម៖

ក. ការជូនដំណឹងពីសំណាក់អង្គជំនុំជម្រះអំពីប្រក្រតិទិនច្បាស់លាស់នៃសវនាការ ដែលនឹងត្រូវធ្វើរហូតដល់ពេលមានការសន្និដ្ឋានលើសំណុំរឿង ០០២/០១។

ខ. ការជូនដំណឹងពីសំណាក់អង្គជំនុំជម្រះអំពីបញ្ជីស្ថាពរ និងមានសម្អាងហេតុច្បាស់លាស់នៃបុគ្គលដែលអង្គជំនុំជម្រះមានបំណងកោះហៅឲ្យមកផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២/០១។

គ. ការត្រួតពិនិត្យឡើងវិញលើប្រក្រតិទិន ដែលកំណត់កាលបរិច្ឆេទនៃការដាក់សេចក្តីសន្និដ្ឋានបញ្ចប់ និងចំនួនទំព័រដែលអនុញ្ញាតដល់ភាគីក្នុងការធ្វើសេចក្តីសន្និដ្ឋាននោះ។

ឃ. ការផ្តល់សេចក្តីពន្យល់ពីសំណាក់អង្គជំនុំជម្រះ ពាក់ព័ន្ធនឹងវិធីសាស្ត្រដែលអង្គជំនុំជម្រះមានបំណងប្រកាន់យក ក្នុងការរៀបចំសវនាការការពារបញ្ចប់ (ជាពិសេសអំពីកាលបរិច្ឆេទ និងរយៈពេលនៃសវនាការ)។ ព័ត៌មាននេះមានសារៈសំខាន់ដល់ភាគីក្នុងការត្រៀមរៀបចំការងាររបស់ខ្លួនឲ្យមានប្រសិទ្ធភាព។

---

[9] *សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣* ឯកសារ **E284** ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ កថាខណ្ឌ ៥៤។

[10] វិធាន ៧៩ (៧) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ចែងថា៖ "ដើម្បីសម្របសម្រួលដល់ការប្រព្រឹត្តទៅនៃកិច្ចដំណើរការនីតិវិធីប្រកបដោយយុត្តិធម៌ និងឆាប់រហ័ស អង្គជំនុំជម្រះសាលាដំបូងអាចពិគ្រោះយោបល់ជាមួយភាគីទាំងឡាយ ដោយធ្វើការប្រជុំរៀបចំសវនាការ ប្រសិនបើយល់ឃើញថាចាំបាច់។ កិច្ចប្រជុំនោះត្រូវធ្វើឡើងជាសម្ងាត់ លើកលែងតែអង្គជំនុំជម្រះសាលាដំបូងសម្រេចផ្សេងពីនេះ។ គោលបំណងនៃការប្រជុំនេះនឹងអនុញ្ញាតឲ្យមានការផ្លាស់ប្តូរមតិយោបល់គ្នារវាងភាគីទាំងឡាយ ដើម្បីសម្របសម្រួលការកំណត់កាលបរិច្ឆេទនៃការធ្វើសវនាការបឋម សវនាការនៃអង្គសេចក្តី និងពិនិត្យឡើងវិញនូវរឿងក្តី ដោយអនុញ្ញាតឲ្យជនជាប់ចោទលើកឡើងនូវបញ្ហាទាំងឡាយទាក់ទងនឹងរឿងក្តីនោះ រួមទាំងស្ថានភាពរូបកាយ និងស្មារតី"។

១២. សហមេធាវីការពារក្តីសង្កត់ធ្ងន់លើសារៈសំខាន់ដែលថា អង្គជំនុំជម្រះត្រូវស្តាប់ហេតុផលរបស់មេធាវីការពារក្តីជាមុនសិន មុនពេលដែលអង្គជំនុំជម្រះចេញសេចក្តីសម្រេចស្ថាពរពាក់ព័ន្ធនឹងចំណុចទាំងអម្បាលម៉ាននេះ។

១៣. **ហេតុដូច្នេះ** ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន សូមស្នើដល់អង្គជំនុំជម្រះសាលាដំបូងមេត្តា៖

- **រៀបចំ**កិច្ចប្រជុំរៀបចំសវនាការមួយដើម្បីស្តាប់ហេតុផលរបស់ភាគីជាមុនសិន មុនពេលអង្គជំនុំជម្រះសម្រេចកំណត់ប្រក្រតិទិនសវនាការដែលនៅសេសសល់ត្រូវធ្វើ ក្នុងក្របខណ្ឌនៃសំណុំរឿង ០០២/០១។
- ~~**ដាក់បញ្ចូលទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំរៀបចំសវនាការ នូវចំណុចនានាដូចខាងក្រោម៖**~~
- ការជូនដំណឹងពីសំណាក់អង្គជំនុំជម្រះ អំពីបញ្ជីស្ថាពរ និងមានសម្អាងហេតុច្បាស់លាស់នៃបុគ្គលដែលអង្គជំនុំជម្រះមានបំណងកោះហៅឲ្យចូលមកផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២/០១។
- **ពិភាក្សា**អំពីកាលបរិច្ឆេទនៃការដាក់សេចក្តីសន្និដ្ឋានបញ្ចប់ ព្រមទាំងចំនួនទំព័រនៃសេចក្តីសន្និដ្ឋានបញ្ចប់របស់ភាគីនីមួយៗ ដោយយោងលើផលវិបាកនានាដែលបង្កើតឡើងដោយមរណភាពរបស់ជនជាប់ចោទ អៀង សារី។
- **ពិភាក្សា**អំពីវិធីសាស្ត្រនៃការរៀបចំសវនាការការពារបញ្ចប់ និងជាពិសេសអំពីរយៈពេលដែលត្រូវផ្តល់ដល់ភាគីនីមួយៗក្នុងការធ្វើសេចក្តីសន្និដ្ឋានរបស់ខ្លួន។

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន<br><br>មេធាវី Anta GUISSÉ<br><br>មេធាវី Arthur VERCKEN<br><br>មេធាវី Jacques VERGÈS | ទីក្រុងភ្នំពេញ<br><br>ទីក្រុងប៉ារីស<br><br>ទីក្រុងប៉ារីស<br><br>ទីក្រុងប៉ារីស | |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |